ជីដូនជីតា និងសាច់ញាតិ

តើអ្នកដឹងអំពីសេវា និងការគាំទ្រសម្រាប់អ្នក និងកុមារៗដែលស្ថិតនៅក្រោមការថែទាំរបស់អ្នកដែរឬទេ?

Washington State
Department of Social
& Health Services

Transforming lives

មានជីដូនជីតាជាង 43,000 នាក់ និងសាច់ញាតិផ្សេងទៀតកំពុងចិញ្ចឹមកុមារ នៅរដ្ឋវ៉ាស៊ីនតោន។ ខាងក្រោមគឺជាធនធាន ផលប្រយោជន៍ និងសេវាគាំទ្រផ្សេងៗដែលអ្នកអាចស្វែងរកបានតាមរយៈក្រសួងសេវាសង្គម និងសុខាភិបាល (DSHS) និងទីភ្នាក់ងារសាធារណៈ និងឯកជនផ្សេងទៀត។

ធនធានទូទៅ និងទូទាំងរដ្ឋ

- **សន្តិសុខសង្គម -** សម្រាប់ព័ត៌មានស្តីពីផលប្រយោជន៍សោធនវិវត្តន៍ និងពិការភាពផ្នែកសន្តិសុខសង្គម លេខទូរស័ព្ទសន្តិសុខសង្គម និងប្រធានបទដែលពាក់ព័ន្ធ ៖
  ទូរស័ព្ទ ៖ 1-800-772-1213 (TTY 1-800-325-0778)
  វិប ៖ www.ssa.gov

- **មជ្ឈមណ្ឌលគ្រប់គ្រងសារធាតុពុលវ៉ាស៊ីនតោន (WAPC)** ផ្តល់ជំបូន្មាន និង ជំនួយលើការព្យាបាលភ្ញាមៅ 24/7 ដោយឥតគិតថ្លៃ និងប្រកបដោយភាពជំនាញ តាមរយៈទូរស័ព្ទក្នុងករណីមានការប្រឈម។ រាល់ការហៅទូរស័ព្ទត្រូវបានរក្សាជាការសម្ងាត់ ៖
  ទូរស័ព្ទ ៖ 1-800-222-1222
  វិប ៖ www.wapc.org

- **អ្នកទាំផ្លូវសាច់ញាតិ (Kinship Navigators)** គឺជាហាងដែលផ្តល់សេវា ជាច្រើននៅក្នុងហាងតែមួយ មានផ្តល់ព័ត៌មាន និងជំនួយដល់សាច់ញាតិដែលអាច មិនបានដឹងអំពីកន្លែងដាក់ពាក្យស្នើសុំផលប្រយោជន៍ និងសេវានានានៅក្នុងសហគមន៍របស់ពួកគេ។ អ្នកទាំផ្លូវសាច់ញាតិ មានបម្រើសេវានៅក្នុងតំបន់ភាគច្រើននៃរដ្ឋ។ អ្នកទាំផ្លូវតាមកុលសម្ព័ន្ធផ្តល់សេវាដល់កុលសម្ព័ន្ធដែលត្រូវបានជ្រើសរើស ៖
  ទូរស័ព្ទ ៖ 1-800-422-3263 ឬ 360-725-2556
  វិប ៖ www.dshs.wa.gov/altsa/home-and-community-services-kinship-care/kinship-care.

- **ក្រុមគាំទ្រក្នុងមូលដ្ឋានសម្រាប់សាច់ញាតិដែលចិញ្ចឹមកុមារ ៖**
  ទូរស័ព្ទ ៖ 1-800-422-3263 ឬ 360-725-2556
  វិប ៖ www.dshs.wa.gov/ (ចុចលើ "ក្រុមគាំទ្រ ..." និង ជ្រើសរើសខោនធី ឬទីក្រុងរបស់អ្នក)

ម៉ើលណា អាយុ 6 ឆ្នាំ សម្រាងនៃការប្រកួតប្រជែងរបស់កុមារ ឆ្នាំ 2016។

- **ខ្សែទូរស័ព្ទបន្ទាន់នៅកន្លែងដែលទៅដល់ (WithinReach hotline)** ផ្តល់ព័ត៌មាន និងបុគ្គលយោងសម្រាប់សេវាសុខាភិបាល និងសេវាសង្គមដែលពាក់ព័ន្ធ នឹងការចិញ្ចឹមកុមារគ្រប់វ័យទាំងអស់ ដែលរួមបញ្ចូលទាំង ការធានារ៉ាប់រងសុខភាព អាហារូបត្ថម្ភ ការពង្រឹងប្រព័ន្ធភាពសាំ ការថែទាំកុមារ ការអភិវឌ្ឍរបស់កុមារ និងកុមារដែលមានតម្រូវការពិសេសផងដែរ ៖
  ទូរស័ព្ទ ៖ 1-800-322-2588 (TTY 711)
  វិប ៖ www.parenthelp123.org (ក្រុមគ្រូសារទាំងឡាយអាចស្វែងរក និងដាក់ពាក្យស្នើសុំសម្រាប់កម្មវិធីនានាដោយប្រើប្រាស់អ្នកស្វែងរកផលប្រយោជន៍)

- **គេហទំព័រទំនាក់ទំនងវ៉ាស៊ីនតោន** ផ្តល់ព័ត៌មាន និងជំនួយដល់ការដាក់ពាក្យស្នើសុំ សេវា DSHS ដែលរួមបញ្ចូលទាំងអំណោយ TANF និងជំនួយផ្នែកស្បៀង អាហារផងដែរ ៖
  វិប ៖ www.washingtonconnection.org

- **បក្សសម្ព័ន្ធសម្រាប់ភាពល្អប្រសើរផ្នែកសុខមាលភាពរបស់កុមារ** ផ្តល់ថ្នាក់ បណ្តុះបណ្តាលសម្រាប់ទាំងសាច់ញាតិ និងឪពុកម្តាយចិញ្ចឹម។ ថ្នាក់បណ្តុះបណ្តាល ទានាតែងតែត្រូវបានធ្វើឡើងនៅពេលយប់ថ្ងៃធ្វើការ និងថ្ងៃចុងសប្តាហ៍ និងមានការ បណ្តុះបណ្តាលមួយចំនួននៅតាមប្រព័ន្ធអ៊ីនធឺណិត។
  វិប ៖ https://allianceforchildwelfare.org/resources

- **រដ្ឋបាលរបស់កុមារ DSHS ៖** ព័ត៌មានអំពីការថែទាំរបស់សាច់ញាតិ ការថែទាក្នុងការចិញ្ចឹមបីបាច់ និងប្រព័ន្ធសុខមាលភាពកុមារ ៖
  វិប ៖ www.dshs.wa.gov/CA/fos/relatives-caring-for-kids

- **គម្រោងយុត្តិធម៌ភាគពាយព្យ (NJP)** ផ្តល់ព័ត៌មានស្តីពីការជួយខ្លួនឯងដោយឥតគិតថ្លៃដែលរួមបញ្ចូលទាំងវ៉ែបសាយត៍ និងខ្សែទូរស័ព្ទបន្ទាន់ហៅចេញដោយឥតគិតថ្លៃផងដែរ។ កម្មវិធីអប់រំ ជំបូន្មាន និងបុគ្គលយោងផ្នែកច្បាប់ដែលត្រូវបាន សម្របសម្រួលរបស់ NJP ផ្តល់ជំនួយផ្នែកច្បាប់ចំពោះបញ្ហាច្បាប់រដ្ឋប្បវេណី សម្រាប់បុគ្គលដែលមានប្រាក់ចំណូលទាបដែលមានសិទ្ធិទទួលបានដោយឥតគិតថ្លៃ។
  ទូរស័ព្ទ ៖ 1-888-201-1014 - ប្រសិនបើអ្នកមានអាយុក្រោម 60 ឆ្នាំ និងមានប្រាក់ចំណូលទាប។ ទីវាសនជនទៃខោនធីយើងគួរហៅទូរស័ព្ទទៅកាន់លេខ 206-464-1519។ ប្រសិនបើអ្នកមានអាយុលើស 60 ឆ្នាំ ដែលមានប្រាក់ចំណូលទៅកម្រិតណាមួយ សូមហៅទូរស័ព្ទទៅកាន់លេខ 1-888-387-7111។

- **ជំនួយផ្នែកច្បាប់វ៉ាស៊ីនតោន** ផ្តល់សេវាផ្នែកច្បាប់សម្រាប់បុគ្គលដែលមានប្រាក់ចំណូលទាប និងមានវ័យចំណាស់នៅក្នុងរដ្ឋវ៉ាស៊ីនតោន។ វ៉ែបសាយត៍ផ្តល់សម្ភារ និងឧបករណ៍អប់រំផ្នែកច្បាប់ដែលផ្តល់ព័ត៌មានមូលដ្ឋានអំពីបញ្ហាច្បាប់ និងសេចក្តីណែនាំលម្អិត និងទម្រង់ទានា ដើម្បីជួយអ្នកក្នុងការតំណាងខ្លួនអ្នកនៅក្នុងតុលាការ។ អ្នកក៏ស្វែងរកព័ត៌មានស្តីពីកម្មវិធីជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ សិទ្ធិទទួលបានជាមូលដ្ឋាន និងព័ត៌មានទំនាក់ទំនងផងដែរ។
  វិប ៖ www.washingtonlawhelp.org

រូបគំនូរនានាបានមកពីការប្រកួតសម្រាងប្រចាំឆ្នាំរបស់កុមារដែលបានចិញ្ចឹមដោយ ជីដូនជីតា និងសាច់ញាតិផ្សេងទៀត ដែលទទួលបានការសហការឧបត្ថម្ភពី DSHS និងសម្របសម្រួលដោយសេវាអប់រំ និងគាំទ្រគ្រួសារ

អ្នក និងកុមារៗដែលស្ថិតនៅក្រោមការថែទាំរបស់អ្នកអាចមានសមត្ថភាពគ្រប់គ្រាន់សម្រាប់

ជំនួយផ្នែកហិរញ្ញវត្ថុ

- **TANF (ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រីក្រ) អំណោយសម្រាប់កុមារ តែប៉ុណ្ណោះ ៖** អំណោយដាសាច់ប្រាក់ប្រចាំខែអាចត្រូវទទួលបានដោយសាច់ញាតិ ដែលជាអ្នកថែទាំបឋម និងចិញ្ចឹមកុមារ។ គេនឹងធ្វើការពិចារណាទាំងប្រាក់ចំណូល របស់កុមារ និងរបស់អ្នកថែទាំ ប៉ុន្តែមានតែធនធានរបស់កុមារប៉ុណ្ណោះដែលត្រូវបានរួមបញ្ចូលនៅក្នុងកំណត់អំពីសិទ្ធិទទួលបាន (ប្រាក់ចំណូលរបស់អ្នកមើលថែទាំ មិនត្រូវបានគេពិចារណាឡើយ ប្រសិនបើកុមារម្នាក់ត្រូវបានរៀបចំខ្ចីនៅក្រោមការថែទាំដោយទីភ្នាក់ងារសុខមាលភាពកុមារ ហើយករណីនោះគឺបើកចំហរ)។ អ្នក មើលថែទាំក៏មានសិទ្ធិទទួលបានអំណោយ TANF សម្រាប់ខ្លួនពួកគេផងដែរ ប្រសិនបើពួកគេចំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់សិទ្ធិទទួលបាន។ អ្នកទទួលអំណោយ TANF សម្រាប់កុមារតែប៉ុណ្ណោះ អាចទទួលបានការទូទាត់ដាសាច់ប្រាក់តែម្តងបន្ថែមទៀតសម្រាប់ជំនួយដល់តម្រូវការក្នុងគ្រួសារ ឬតម្រូវការសម្ភារៈប្រើប្រាស់ក្នុងគ្រាអាសន្នតាមរយៈកម្មវិធីលក្ខខណ្ឌតម្រូវបន្ថែមសម្រាប់តម្រូវការក្នុងគ្រាអាសន្ន (AREN)។ ចូរសាកសួរ CSO ក្នុងមូលដ្ឋានរបស់អ្នកអំពីមូលនិធិទាំងនេះ។

  ទូរស័ព្ទ ៖ 1-877-501-2233 ដើម្បីស្វែងរកការិយាល័យសេវាសហគមន៍ក្នុងមូលដ្ឋានរបស់អ្នក។
  វិប ៖ www.dshs.wa.gov/esa/esa-find-office
  ដើម្បីមើលថាតើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់ដែរឬទេ និងដើម្បីដាក់ពាក្យស្នើសុំជំនួយ សូមចូលទៅកាន់ www.washingtonconnection.org

- **កម្មវិធីគាំទ្រអ្នកថែទាំដែលជាសាច់ញាតិ (KCSP) ៖** សាច់ញាតិដែលចិញ្ចឹមកុមារ ដែលមិនបានចូលរួមនៅក្នុងប្រព័ន្ធសុខមាលភាពកុមារអាចទទួលបានមូលនិធិរយៈពេលខ្លី ដើម្បីជួយដល់ការទូទាត់ប្រាក់សម្រាប់តម្រូវការមូលដ្ឋាន (ចំណីអាហារ ផ្ទះសម្បែង សម្ភៃកបំពាក់ សម្ភារៈសិក្សា។លទ)
  វិធីដាក់ពាក្យស្នើសុំ ៖

  ទូរស័ព្ទ ៖ រដ្ឋបាលមនុស្សចាស់ និងការគាំទ្ររយៈពេលវែង តាមរយៈលេខ 1-800-422-3263 ឬ 360-725-2556 ដើម្បីស្វែងរកការិយាល័យ KCSP ក្នុងមូលដ្ឋាន
  វិប ៖ www.dshs.wa.gov/altsa/hcs/kinship-care/benefits
  (ចុចលើជំនួយផ្នែកហិរញ្ញវត្ថុ)

- **មូលនិធិសេវាគាំទ្រសាច់ញាតិ** ផ្តល់មូលនិធិក្នុងគ្រាអាសន្នរយៈពេលខ្លីដល់សាច់ញាតិដែលគ្មានអាជ្ញាប័ណ្ណ និងអ្នកថែទាំកុមារក្នុងបន្ទុករបស់រដ្ឋ ដែលបានអនុម័តផ្សេងទៀត (កុមារក្នុងបន្ទុករបស់រដ្ឋ គឺជាកុមារដែលស្ថិតនៅក្រោមការ ចិញ្ចឹមបីបាច់ដោយស្រុបច្បាប់របស់រដ្ឋ ដែលមានរឿងក្តីបើកចំហរួមជាមួយ រដ្ឋបាលកុមារ និងបុគ្គលិកសង្គមដែលត្រូវបានចាត់តាំង)។ មូលនិធិនានាអាចទូទាត់ ប្រាក់ថ្ងៃត្រឿងសង្ហរិម ថ្ងៃសម្ភៃកបំពាក់ ថ្ងៃហ្គាស ប្រាក់តម្កល់ សម្ភារៈសិក្សា។ល។ ទាក់ទងបុគ្គលិកសង្គមរបស់កុមារដើម្បីទទួលបានមូលនិធិទាំងនេះ ឬសម្រាប់ ព័ត៌មានបន្ថែម។ ឪពុកម្តាយចិញ្ចឹមពុំមានសិទ្ធិទទួលបាននោះទេ។



អាម៉ារីស អាយុ 17 ឆ្នាំ សម្រាងនៃការប្រកួតប្រជែងរបស់កុមារ ឆ្នាំ 2016។

ការថែទាំសុខភាព

- **ការធានារ៉ាប់រងសុខភាពសម្រាប់កុមារដែលស្ថិតនៅក្រោមការថែទាំរបស់សាច់ញាតិ ៖** កុមារដែលរស់នៅជាមួយអ្នកថែទាំដែលជាសាច់ញាតិអាចមានសិទ្ធិទទួលបានការធានារ៉ាប់រងសុខភាពផ្ទៃបៅមវ៉ាស៊ីនតោនដោយឥតគិតថ្លៃ។ ពាក្យស្នើសុំមួយត្រូវតែបានដាក់ជូនតាមប្រព័ន្ធអ៊ីនធឺណិត ឬតាមរយៈការហៅទូរស័ព្ទ ទៅកាន់មជ្ឈមណ្ឌលសេវាអតិថិជន។ អ្នកថែទាំក៏អាចមានសិទ្ធិទទួលបានធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាបសម្រាប់ខ្លួនពួកគេបានផងដែរ នៅអាចដាក់ពាក្យស្នើសុំក្នុងពេលតែមួយដែលពួកគេដាក់ពាក្យស្នើសុំសម្រាប់កុមារដែលស្ថិតក្រោមការមើលថែទាំរបស់ពួកគេផងដែរ។

  ទូរស័ព្ទ ៖ 1-855-923-4633
  វិប ៖ www.wahealthplanfinder.org

- **ការធានារ៉ាប់រងសុខភាពសម្រាប់កុមារដែលស្ថិតនៅក្រោមការថែទាំរបស់ឪពុក ម្តាយចិញ្ចឹម ៖** កុមារដែលស្ថិតនៅក្នុងបន្ទុករបស់រដ្ឋមានសិទ្ធិទទួលបានការធានារ៉ាប់រងសុខភាពផ្ទៃបៅមវ៉ាស៊ីនតោនដោយស្វ័យប្រវត្តិ និងពុំចាំបាច់ដាក់ពាក្យស្នើសុំអ្វីឡើយ។ រដ្ឋបាលកុមាររាយការណ៍អំពីកុមារដែលទទួលបានការថែទាំទៅកាន់ អាជ្ញាធរថែទាំសុខភាពដោយផ្ទាល់។

- **ទំនាក់ទំនងសន្សំលក្ខណៈសុខភាពផ្ទៃបៅម (AHCC)** ដោះស្រាយចំពោះតម្រូវការក្នុងការថែទាំសុខភាពរបស់កុមារដែលស្ថិតក្នុងបន្ទុករបស់រដ្ឋដែលត្រូវបានរៀបចំខ្ចីត ក្រោមការថែទាំនៅខាងក្រៅផ្ទះ។ AHCC អាចជួយសម្តាប់សេវា ឬអ្នកផ្តល់សេវាណាខ្លះដែលកុមាររបស់អ្នកត្រូវការជួយសម្តាប់បញ្ហាសុខភាពមុន។សម្រាប់កុមារ ដែលត្រូវបានរៀបចំខ្ចីតស្ថិតក្រោមការថែទាំថ្មីៗ ឆ្លើយតបទិដ្ឋភាពសំណួរនានាស្តីពីបញ្ហា សុខភាពរបស់កុមារ និងជួយដល់ការទាំផ្ទៃប្រព័ន្ធថែទាំសុខភាពផ្ទៃបៅមវ៉ាស៊ីនតោន និងប្រព័ន្ធថែទាំសុខភាពដែលកាន់តែអស្ចារ្យដាងនេះទៀត។ កុមារមានសិទ្ធិទទួល បាន AHCC ប្រសិនបើពួកគេមានអាយុក្រោម 21 ឆ្នាំ និងនៅក្នុងការរៀបចំខ្ចីតក្រោមការថែទាំតាមរយៈកុលសម្ព័ន្ធ ឬការស្ថិតក្នុងបន្ទុករបស់រដ្ឋ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងបុគ្គលិកសង្គមរបស់កុមាររបស់អ្នក ឬ ៖

  ទូរស័ព្ទ ៖ 1-844-354-9876

- **សម្ភារៈសម្រាប់លើកតម្លើងប្រវត្តិរូបសុខភាពរបស់កុមារ** អាចរកបានសម្រាប់កុមារ ចាប់តាំងពីពេលចាប់កំណើតរហូតដល់កុមារមានអាយុប្រាំមួយឆ្នាំ។ ព័ត៌មានមាន ភាពដាក់លាក់តាមអាយុ និងរួមបញ្ចូលការពង្រឹងប្រព័ន្ធភាពសាំ ការលូតលាស់ ការអភិវឌ្ឍ សុវត្ថិភាព អាហារូបត្ថម្ភ និងបញ្ហានៃភាពដាច់ឪពុកម្តាយផ្សេងទៀត។

  ទូរស័ព្ទ ៖ 1-866-397-0337
  វិប ៖ www.childprofile.org

- **ការផ្តល់ជូនគ្មានថ្លៃតាមព័ត៌មានការពង្រឹងប្រព័ន្ធភាពសាំរបស់កុមារ** (ក្រសួងបោះពុម្ពផ្សាយ អំពីសុខភាព លេខ 348-080) ៖ ព័ត៌មានលម្អិតដើម្បីជួយដាច់ឪពុកម្តាយ និងអ្នកថែទាំ ធ្វើការសម្រេចដោយមានព័ត៌មានគ្រប់គ្រាន់អំពីការពង្រឹងប្រព័ន្ធភាពសាំរបស់ភ្ជាន។ និងកុមាររបស់ពួកគេ។ ដើម្បីទទួលបានស្បៃវ៉ែតាស្ពើង និងឯកសារអំពីការពង្រឹង ប្រព័ន្ធភាពសាំផ្សេងៗ។ទៀតដោយឥតគិតថ្លៃ ៖

  ទូរស័ព្ទ ៖ 1-866-397-0337
  វិប ៖ http://here.doh.wa.gov/materials/plaintalk

- **មណ្ឌលសុខភាពដែលទទួលយកការធានារ៉ាប់រងសុខភាពផ្ទៃបៅមវ៉ាស៊ីនតោន**
  សម្រាប់ការថែទាំជំងឺ និងការថែទាំផ្ទៃកទន្ទសាស្ត្រ ៖

  ទូរស័ព្ទ ៖ 1-800-562-3022
  វិប ៖ https://fortress.wa.gov/hca/p1findaprovider/
  អ្នកថែទាំត្រូវតែទាក់ទងអ្នកផ្តល់សេវាដើម្បីទទួលបានព័ត៌មានថាតើពួកគេកំពុងទទួលអ្នកជំងឺនៃកម្មវិធីសុខភាពផ្ទៃបៅមថ្មីៗ។ទៀតដែរឬទេ។

- **ការយល់ព្រមដែលមានព័ត៌មានគ្រប់គ្រាន់សម្រាប់ការថែទាំដ៏ធ** - ច្បាប់រដ្ឋអនុញ្ញាត ឲអ្នកថែទាំដែលជាសាច់ញាតិផ្តល់ការយល់ព្រមដែលមានព័ត៌មានគ្រប់គ្រាន់ចំពោះការថែទាំដ៏ធសម្រាប់កុមារដែលស្ថិតក្រោមការថែទាំរបស់ពួកគេ (រួមបញ្ចូលទាំង ការថែទាំផ្នែកទន្តសាស្ត្រ និងការថែទាំសុខភាពខ្លួនក្សាលផងដែរ) ទោះបីជាពួកគេ គ្មានផីកាពីតុលាការក៏ដោយ។ នៅពេលថែទាំកុមារដែលស្ថិតក្រោមការចិញ្ចឹម បីបាច់របស់រដ្ឋ អ្នកត្រូវតែនិយាយជាមួយបុគ្គលិកសង្គមដើម្បីយល់ដឹងអំពីការថែទាំ ជំនួយដ៏ធ ដែលតុលាការត្រូវតែអនុម័ត។ សម្រាប់ព័ត៌មានបន្ថែម ចូរមើលនៅក្រោម "ការ លោះកម្ពស្តផ្សាយដោយឥតគិតថ្លៃ" ជាកន្លែងដែលអ្នកអាចដោនឡូតកូនស្សេរភ្លា ផ្សព្វផ្សាយ *ការយល់ព្រមចំពោះការថែទាំសុខភាពសម្រាប់កុមារដែលស្ថិតនៅក្រោមការថែទាំរបស់អ្នក ៖ ការណែនាំរបស់អ្នកថែទាំដែលជាសាច់ញាតិ*។

  ទូរស័ព្ទ ៖ 1-800-422-3263 or 360-725-2556 ដើម្បីទទួលបានសំណៅ ចម្លងមួយច្បាប់អំពីកូនស្សេរភ្លាផ្សព្វផ្សាយអំពីការយល់ព្រមដែលមានព័ត៌មានគ្រប់គ្រាន់។
  វិប ៖ www.washingtonlawhelp.org/issues/family-law/non-parents-caring-for-children

សេវាផ្នែកទន្តសាស្ត្រ

- **ការស្វែងរកការថែទាំផ្នែកទន្តសាស្ត្រសម្រាប់កុមារ និងមនុស្សពេញវ័យ ៖**

  វិប ៖ www.theMightyMouth.org បញ្ជីឈ្មោះមន្ទីរសម្រាកព្យាបាលមាត់ធ្មេញក្នុងតម្លៃទាបតាមខោនធី
  ទូរស័ព្ទ ៖ 2-1-1 បណ្តាញព័ត៌មានវ៉ាស៊ីងតោន (WIN) ពីគ្រប់ទីកន្លែងទាំងអស់នៅក្នុងរដ្ឋវ៉ាស៊ីងតោន ដើម្បីនិយាយទៅកាន់អ្នកឯកទេសផ្នែកព័ត៌មាន និងបុគ្គលយោង សម្រាប់ជំនួយក្នុងការស្វែងរកព័ត៌មានទំនាក់ទំនងផ្នែកទន្តសាស្ត្រនៅក្នុងមូលដ្ឋាន (មានអ្នកបកប្រែ)
  វិប ៖ ក្រសួងសុខាភិបាលនៃរដ្ឋវ៉ាស៊ីងតោនសម្រាប់ធនធានផ្នែកសុខភាពមាត់ធ្មេញ ៖ www.doh.wa.gov/YouandYourFamily/OralHealth/FindingDentalCare

- **មជ្ឈមណ្ឌលទន្តសាស្ត្រកុមារ (CPD)** ជាការសហការគ្នារវាងសាកលវិទ្យាល័យ វ៉ាស៊ីងតោន និងមន្ទីរពេទ្យកុមារសេអាថល ផ្តល់ការថែទាំមាត់ធ្មេញគ្រប់ជ្រុងជ្រោយ និងមានឯកទេសដល់កុមារគ្រប់វ័យ រួមបញ្ចូលទាំងកុមារដែលមានតម្រូវការពិសេស ផងដែរ។ កម្មវិធីថែទាំសុខភាពផ្ទៃបោ៉ាមបានទទួលយ៉ាក។

  ទូរស័ព្ទ ៖ 206-543-5800
  វិប ៖ www.thecenterforpediatricdentistry.com

ជំនួយផ្នែកសុខភាពខ្លួនក្សាល និងវិបល្វាសក្នុងការប្រើប្រាស់សារធាតុ

- ដើម្បីស្វែងរកសេវា និងទីភ្នាក់ងារនានាក្នុងមូលដ្ឋានដែលបម្រើសេវាដល់កុមារ យុវវ័យ និងក្រុមគ្រួសារដែលបានចុះឈ្មោះនៅក្នុងកម្មវិធីថែទាំសុខភាពផ្ទៃបោ៉ាម ៖

  ទូរស័ព្ទ ៖ ខ្សែទូរស័ព្ទជំនួយដល់ការស្តារស្ថានភាពវ៉ាស៊ីងតោន ៖ 1-866-789-1511 សម្រាប់ការគាំទ្រ និងបុគ្គលយោងផ្នែកអារម្មណ៍
  វិប ៖ https://www.dshs.wa.gov/bha/

- **កម្មវិធីផ្តល់សេវាគ្រប់ជ្រុងជ្រោយ និងបន្ទាន់របស់រដ្ឋវ៉ាស៊ីងតោន (WISe)** ផ្តល់សេវាសុខភាពផ្នែកអាកប្បកិរិយាគ្រប់ជ្រុងជ្រោយនៅតំបន់ជាច្រើនរបស់រដ្ឋ ដែល ការអនុវត្តពេញលេញត្រូវបានកំណត់សម្រាប់ឆ្នាំ 2018។ WISe ផ្តល់ការគាំទ្រ ដល់យុវជនដែលមានសិទ្ធិទទួលបានកម្មវិធីថែទាំសុខភាពផ្ទៃបោ៉ាម ដែលមានអាយុ រហូតដល់ 21 ឆ្នាំ ដែលមានតម្រូវការផ្នែកអាកប្បកិរិយាស្មុគស្មាញ និងក្រុមគ្រួសារ របស់ពួកគេ។

  វិប ៖ https://www.dshs.wa.gov/sites/default/files/CA/cp/documents/WISeCONACTS.pdf

- សម្រាប់ព័ត៌មានស្តីពីការទប់ស្កាត់ និងសេវានានា សូមចូលទៅកាន់ https://www.dshs.wa.gov/bha/division-behavioral-healthand-recovery/substance-abuse-prevention-and-mentalhealth-promotion

- សម្រាប់ព័ត៌មានស្តីពីការទប់ស្កាត់ការប្រើប្រាស់សារធាតុនានាមុនអាយុ សូមចូល ទៅកាន់ www.StartTalkingNow.org។

ជំនួយផ្នែកតម្រូវការពិសេស

- **ការគាំទ្រនៅនៅដំណាក់កាលដំបូងសម្រាប់ទារក និងកុមារទាបជាងនេះ និងកុមារទាមទារនូវការគាំទ្ររយៈពេលវែង (ESIT)** ផ្តល់សេវាអន្តរាគមន៍សម្រាប់កុមារចាប់ពីពេលចាប់កំណើត រហូតដល់កុមារ មានអាយុបីឆ្នាំ។ ប្រសិនបើអ្នកថែទាំកុមារពិការ ឬអ្នកមានកង្វល់ អំពីការអភិវឌ្ឍ របស់កុមារ សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទបន្ទាន់ផ្នែកសុខភាព គ្រួសារតាមរយៈលេខ 1-800-322-2588។ ស្នើសុំឈ្មោះរបស់អ្នកសម្របសម្រួលធនធានគ្រួសារ (FRC) នៅក្នុងសហគមន៍ក្នុងមូលដ្ឋានរបស់អ្នកដើម្បីមើលថាតើកុមាររបស់អ្នកមានសិទ្ធិទទួលបានសេវា ESIT ដែរឬទេ។

  ទូរស័ព្ទ ៖ 1-800-322-2588 (TTY 711).
  វិប ៖ www.del.wa.gov/esit

- **រដ្ឋបាលពិការភាពក្នុងការអភិវឌ្ឍ (DDA)** របស់ DSHS ផ្តល់សេវានានាសម្រាប់អ្នកដែលបានធ្វើរោគវិនិច្ឆ័យហើយឃើញថាមានពិការភាព ឬមានភាពយឺតយ៉ាវផ្នែកបញ្ញា ឬការអភិវឌ្ឍ។ សេវានានា គឺអាស្រ័យលើតម្រូវការ និងការផ្តល់មូលនិធិ។ សេវានានារួមបញ្ចូលការគាំទ្របុគ្គល និងគ្រួសារ ការថែទាំផ្ទះល់ខ្លួន ការគាំទ្រផ្នែកការងារ កម្មវិធីប្រចាំថ្ងៃ និងការថែទាំចំពោះការស្នាក់នៅ។ ដើម្បីទាក់ទងកាំរិយាល័យ DDA ក្នុងមូលដ្ឋានរបស់អ្នក ៖

  វិប ៖ www.dshs.wa.gov/dda និងមើលក្រោម "សិទ្ធិទទួលបាន"

ការថែទាំកុមារ និងការរៀនសូត្រនៅដំណាក់កាលដំបូង

អ្នកថែទាំដែលជាសាច់ញាតិអាចមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានកម្មវិធី ថែទាំកុមារដោយឧបត្ថម្ភកធនរបស់រដ្ឋណាមួយ។ ទាំងនេះរួមមាន ៖

- **ការថែទាំកុមារដែលពាក់ព័ន្ធនឹងការធ្វើការ (WCCC) សម្រាប់អ្នកថែទាំដែលមានការងារធ្វើ**
- **ការថែទាំកុមារតាមរដូវកាលសម្រាប់អ្នកធ្វើការផ្នែককសិកម្មតាមរដូវកាល**
- **ការថែទាំកុមារដែលគ្មានទីលំនៅសម្រាប់គ្រួសារដែលពុំមានទីលំនៅជាបណ្តោះអាសន្ន (ត្រូវបានកំណត់ចំពោះខោនធីមួយចំនួន)**

សម្រាប់ WCCC និងការថែទាំកុមារតាមរដូវកាល នៅក្នុងរឿងក្តីភាគច្រើន អ្នក ថែទាំអាចមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានទោះបីជាមានសាមី/ភរិយា តែម្នាងដែលកំពុងធ្វើការក៏ដោយ។ ប្រសិនបើអ្នកទាំងពីរ គឺជាអាណាព្យាបាលស្របច្បាប់របស់កុមារ និងបានកត់ត្រានៅក្នុងសំណុំឯកសាររបស់តុលាការនោះ អ្នកទាំងពីរត្រូវតែកំពុងធ្វើការដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបាន។ សម្រាប់ការថែទាំកុមារដែលគ្មានទីលំនៅ អ្នកថែទាំមិនត្រូវមានសិទ្ធិទទួលបានកម្មវិធីឧបត្ថម្ភកធនលើការថែទាំកុមារណាមួយផ្សេងទៀតឡើយ ដូចជាការស្វែងរកការងារ ឬទីលំនៅជាដើម។ សាច់ញាតិដែលមានការងារធ្វើ និងថែទាំកុមារដែលស្ថិតក្នុងបន្ទុករបស់រដ្ឋ ក៏អាចមានសិទ្ធិទទួលបានការថែទាំកុមារដែលទទួលបានឧបត្ថម្ភកធនផងដែរ និងគួរទាក់ទងបុគ្គលិកសង្គមរបស់ពួកគេ។

សម្រាប់ WCCC និងការថែទាំកុមារតាមរដូវកាល ៖

  ទូរស័ព្ទ ៖ 1-877-501-2233 សម្រាប់មជ្ឈមណ្ឌលសេវាអតិថិជនរបស់រដ្ឋវ៉ាស៊ីងតោន
  វិប ៖ www.del.wa.gov

ទាក់ទងផ្នែកការយល់ដឹងអំពីការថែទាំកុមារសម្រាប់ព័ត៌មានស្តីពីការថែទាំកុមារផ្សេងទៀត ដែលរួមបញ្ចូលទាំងការថែទាំកុមារគ្មានទីលំនៅផងដែរ

ទូរស័ព្ទ ៖1-800-446-1114
វិប ៖ http://wa.childcareaware.org/families

អាវ៉ែនដា អាយុ 5 ឆ្នាំ សម្រាងនៃការប្រកួតប្រជែងរបស់កុមារ ឆ្នាំ 2004

- **កម្មវិធីម្ហូបអាហារផ្លូវក្តៅ ៖** កុមារគ្រប់រូបដែលមានអាយុ 18 ឆ្នាំ និងក្មេងជាងនេះ ដោយមិនគិតអំពីប្រាក់ចំណូលក្នុងគ្រួសារ មានសិទ្ធិទទួលបានម្ហូបអាហារនៅអង្គភាពទានដែលបម្រើម្ហូបអាហារក្នុងអំឡុងខែទានានៃរដូវក្តៅ។ សម្រាប់ព័ត៌មាន ៖

  ទូរស័ព្ទ ៖1-866-3-HUNGRY

ECEAP (កម្មវិធីអប់រំ និងជំនួយដល់ជំណាក់កាលដំបូងនៃកុមារភាព) និងកម្មវិធី ហ៊ែតស្តាតផ្តល់សេវា និងការគាំទ្រដោយឥតគិតថ្លៃដល់កុមារដែលមានអាយុ 3 និង 4 ឆ្នាំដែលមានកត្តារគ្រោះថ្នាក់ទានា ដែលអាចបង្ហាក់ភាពដោតជ័យក្នុងការ សិក្សា ដែលរួមបញ្ចូលទាំងកុមារដែលស្ថិតនៅក្រោមការថែទាំរបស់សាច់ញាតិ ផងដែរ។

ទូរស័ព្ទ ៖1-866-482-4325
វិប ៖ https://www.del.wa.gov/parents-family/eceap-and-head-start

ការតស៊ូមតិក្នុងការអប់រំ

ការិយាល័យអប់រំ Ombuds (OEO) ដោះស្រាយពាក្យរិះគន់ វិវាទ និងបញ្ហា ទានារវាងគ្រួសារ និងសាលារដ្ឋនៅគ្រប់តំបន់ទាំងអស់ដែលប៉ះពាល់ដល់ការរៀន សូត្ររបស់សិស្សានុសិស្ស។ មុខងាររបស់ OEO មិនស្ថិតនៅក្រោមការគ្រប់គ្រង របស់ប្រព័ន្ធសាលារដ្ឋឡើយ។ សិស្សានុសិស្សអាចទទួលបានសេវាទានាចាប់ពី មត្តេយ្យសិក្សារហូតដល់ថ្នាក់ទី 12 ដោយឥតគិតថ្លៃ និងត្រូវបានការក្សាការសម្ងាត់។ ទាក់ទង OEO នៅពេលដែលបញ្ហាដែលមិនទាន់បានដោះស្រាយជាមួយសាលា រដ្ឋដែលប៉ះពាល់ដល់ការអប់រំរបស់សិស្សានុសិស្ស អ្នកមានបំណងទទួលបានការ វាយតម្លៃឯករាជ្យអំពីស្ថានភាព ឬអ្នកមានសំណួរផ្សេងទៀតអំពីប្រព័ន្ធអប់រំ។

ទូរស័ព្ទ ៖1-866-297-2597
វិប ៖ www.oeo.wa.gov

ជំនួយផ្នែកចំណីអាហារ

- **កម្មវិធីចំណីអាហារមូលដ្ឋានរបស់រ៉ាស៊ីនតោន** សម្រាប់ផលប្រយោជន៍ផ្នែកចំណី អាហារប្រចាំខែ។ ទាក់ទង ៖

  CSO ក្នុងមូលដ្ឋានរបស់អ្នក ៖ ដើម្បីស្វែងរកការិយាល័យសេវាសង្គមក្នុងមូលដ្ឋានរបស់អ្នក សូមហៅទូរស័ព្ទទៅកាន់ 1-877-501-2233 ឬចូលទៅកាន់ ៖ https://www.dshs.wa.gov/esa/esa-find-office

  ដើម្បីមើលឃើញថាតើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានដែរឬទេ និង ដើម្បីដាក់ពាក្យស្នើសុំជំនួយ សូមចូលទៅកាន់ www.washingtonconnection.org

- **កម្មវិធីអាហារូបត្ថម្ភរបស់កុមារ** - ប្រសិនបើកុមារចំពេញតាមគោលការណ៍រំណនាំ អំពីប្រាក់ចំណូលឬទទួលបាន TANF ឬចំណីអាហារមូលដ្ឋាន ពួកគេមានសិទ្ធិ ទទួលបានអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃ ឬដែលមានការ បញ្ចុះតម្លៃនៅសាលារដ្ឋ ឬសាលាឯកជន។ ដើម្បីទទួលបានព័ត៌មានបន្ថែម សូម ទាក់ទងសាលារៀនដែលកុមាររបស់អ្នកកំពុងរៀន។

- **កម្មវិធីចំណីអាហារសម្រាប់ការថែទាំកុមារ និងមនុស្សពេញវ័យ (CACFP)៖** ផ្តល់ម្ហូបអាហារដោយឥតគិតថ្លៃដល់កុមារដែលស្ថិតនៅក្រោមការថែទាំរបស់អង្គភាពទានា ដែលចូលរួមក្នុងកម្មវិធីនេះ។ ទីតាំង CACFP ជាច្រើនផ្តល់អាហារពេលព្រឹក អាហារថ្ងៃត្រង់ និងអាហារសម្រន់។ សាលារដ្ឋ ឬសាលាឯកជនមួយចំនួនផ្តល់ អាហារសម្រន់ និង/ឬម្ហូបអាហារនៅក្រោយថ្ងៃរៀនសូត្រធម្មតា។ ដើម្បីទទួលបាន ព័ត៌មានបន្ថែម សូមទាក់ទងអង្គភាពថែទាំកុមារដែលកុមាររបស់អ្នកកំពុងស្ថិតនៅក្រោមការថែទាំរបស់ពួកគេ។

  វិប ៖ www.fns.usda.gov/summerfoodrocks

- **កម្មវិធីអាហារូបត្ថម្ភរបស់ស្ត្រី ទារក និងកុមារ (WIC)** ជួយកុមារវ័យក្មេងដែលមានអាយុក្រោមប្រាំឆ្នាំ ស្ត្រីមានផ្ទៃពោះ និងអ្នកម្តាយថ្មីៗ ឲទទួលទានអាហារបានល្អ រៀនសូត្រអំពីអាហារូបត្ថម្ភ និងមានសុខភាពល្អ។ សាច់ញាតិ និងវ៉ីពុកម្តាយចិញ្ចឹម ដែលជាអ្នកថែទាំបឋមរបស់កុមារ (អាយុ 0-5 ឆ្នាំ) អាចទទួលបានសេវា WIC សម្រាប់កុមារដែលស្ថិតក្រោមការថែទាំរបស់ពួកគេ។ ក្រៅពីមូលប្បទានបត្រប្រចាំ ខែសម្រាប់ជួយដល់ការទិញចំណីអាហារដែលផ្តល់សុខភាពល្អហើយនោះ WIC ផ្តល់ការអប់រំអំពីអាហារូបត្ថម្ភ និងការត្រួតពិនិត្យសុខភាព និងការបញ្ជូនទៅកាន់មន្ទីរពេទ្យផងដែរ។

- **ដើម្បីស្វែងរកមន្ទីរសម្រាកពេទ្យបាល WIC ប្រសិនបើអ្នកមានសិទ្ធិទទួលបាន ៖**

  ទូរស័ព្ទ ៖ ខ្សែទូរស័ព្ទបន្ទាន់ផ្នែកសុខភាពគ្រួសារ : 1-800-322-2588
  វិប ៖ http://www.doh.wa.gov/YouandYourFamily/WIC/Eligibility

- **ខ្សែបន្ទាត់ចំណីអាហារសម្រាប់គ្រួសារទូទាំងរដ្ឋ** ផ្តល់ព័ត៌មានបន្ថែមអំពីធនធានចំណីអាហារទានាដែលរួមបញ្ចូលទាំងកម្មវិធីចំណីអាហារមូលដ្ឋានរបស់រដ្ឋ ម្ហូបអាហារ រដូវក្តៅសម្រាប់កុមារ ដោយឥតគិតថ្លៃសេវាចំណីអាហារនៅគ្រាអាសន្នក្នុងមូលដ្ឋាន និងកម្មវិធីអាហារូបត្ថម្ភនៅទីផ្សារកសិករដាន់ខ្ពស់ផងដែរ។

  ទូរស័ព្ទ ៖1-888-436-6392

ការគាំទ្រកុមារ

- អ្នកអាចដាក់ពាក្យស្នើសុំសេវាទានានៅផ្នែកគាំទ្រកុមារ (DCS) ទោះបីជាអ្នកមិនទទួលបានជំនួយសាធារណៈណាមួយក៏ដោយ។ ការទទួលបាន TANF ឬប្រភេទមួយចំនួនទៀតជំនួយផ្នែកវេជ្ជសាស្ត្រ នឹងបង្ហាញលទ្ធផលដោយស្វ័យប្រវត្តិនៅក្នុងការបង្កើតរឿងក្តីណាមួយរបស់ DCS។

- ការបង្កើតបិតុភាពរបស់ DCS អាចជួយក្រុមគ្រួសារឲទទួលបានផលប្រយោជន៍ទានាដែលកុមារអាចមានសិទ្ធិទទួលបាន ដូចជាសន្តិសុខសង្គមជាដើម និងជួយផ្តល់ប្រវត្តិជំនឿរបស់គ្រួសារមួយផងដែរ។ ប្រសិនបើអ្នកខ្វាចថាការបង្កើតបិតុភាព ឬការអនុវត្តការគាំទ្រកុមារអាចមានគ្រោះថ្នាក់ចំពោះអ្នក ឬកុមារ សូមទាក់ទង ការិយាល័យសេវាសហគមន៍ក្នុងមូលដ្ឋានរបស់អ្នក ដើម្បីពិភាក្សាអំពី “មូលហេតុស្របច្បាប់” ដែលជាការចោះបង់ការអនុវត្តការគាំទ្រកុមារ។

- DCS នឹងអនុវត្តដីកាគាំទ្រកុមារដែលមានអត្ថិភាពណាមួយ ដូចជាក្រឹត្យលែងលះ ឬ នឹងបង្កើតដីការគាំទ្រណាមួយ ប្រសិនបើចាំបាច់។ DCS កំណត់កាតព្វកិច្ចគាំទ្រ ផ្អែកតាមសមត្ថភាពក្នុងការទូទាត់ប្រាក់របស់មាតា/បិតា។ DCS ក៏មានបំណងឲ មាតាបិតារ៉ាប់រងលើធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្ររបស់កូនៗរបស់ពួកគេដោយផ្ទាល់ផងដែរ ប្រសិនបើមាន។

សម្រាប់ព័ត៌មានអំពីសេវា DCS ទាំងអស់ ៖

ទូរស័ព្ទ ៖1-800-442-KIDS
វិប ៖ https://www.dshs.wa.gov/esa/division-child-support

ការបោះពុម្ពផ្សាយដោយឥតគិតថ្លៃ

អ្នកអាចបញ្ជាទិញការបោះពុម្ពផ្សាយនានាដែលមានលេខបោះពុម្ពផ្សាយរបស់ DSHS ពី Myfulfillment.wa.gov របស់ក្រសួងបោះពុម្ពនៃរដ្ឋវ៉ាស៊ីនតោន។ តាមធម្មតា លេខបោះពុម្ពផ្សាយ គឺនៅទំព័រខាងក្រោយ។ ឧទាហរណ៍ ៖ ការបោះពុម្ពផ្សាយនេះ គឺ DSHS 22-1120។ សំណើសុំការបោះពុម្ពផ្សាយក៏អាចដាក់ដោយ ៖

អ៊ីម៉ែល ៖ Fulfillment@des.wa.gov
ទូរស័ព្ទ ៖ 360-570-5555
ទូរសារ ៖ 360-664-2048

នៅពេលបញ្ជាទិញមានការបោះពុម្ពផ្សាយនានា សូមអ្នកមានលេខបោះពុម្ពផ្សាយ លេខ ឈ្មោះរបស់អ្នក និងអាសយដ្ឋានផ្ទះសម្រាប់ផ្ញើសំបុត្រ។

- **ការយល់ព្រមចំពោះការថែទាំកុមារដែលស្ថិតនៅក្រោមការថែទាំរបស់អ្នក ៖** ការណែនាំរបស់អ្នកថែទាំដែលជាសាច់ញាតិ (DSHS 22-1119)។ ពត្យល់អំពី ច្បាប់នានាដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិរបស់ WA នៅឆ្នាំ 2005-2006 ដែលពណ្ណនាអំពីសិទ្ធិ និងទំនួលខុសត្រូវរបស់សាច់ញាតិ។ ភាសាអង់គ្លេស ភាសាខ្មែរ ភាសារុស្ស៊ី ភាសាសុម៉ាលី ភាសាអេស្ប៉ាញ ភាសា យ៉ូតណាម (PDF)

- **ដីម្ងនជីតា និងសាច់ញាតិ តើអ្នកដឹងអំពីសេវា និងការគាំទ្រសម្រាប់អ្នក និងកុមារៗដែលស្ថិតនៅក្រោមការថែទាំរបស់អ្នកដែរឬទេ?** (DSHS 22-1120)។ បញ្ជីធនធានដ៏ប្រយោជន៍ និងសេវាគាំទ្រដែលសាច់ញាតិដែលចិញ្ចឹមកុមារៗអាច ស្វែងរកបាន។ ភាសាអង់គ្លេស ភាសាខ្មែរ ភាសាចិន ភាសាកូរ៉េ ភាសាឡាវ ភាសារុស្ស៊ី ភាសាសុម៉ាលី ភាសាអេស្ប៉ាញ ភាសាយ៉ូតណាម (PDF)

- **ការណែនាំអំពីការតស៊ូមតិក្នុងការអប់រំសម្រាប់អ្នកផ្តល់ការថែទាំ - ការគាំទ្រភាពជោគជ័យរបស់សាលារៀនដើម្បីកុមារ និងយុវជនដែលស្ថិតនៅក្រោមការថែទាំ** (DSHS 22-1192)។ ជួយអ្នកផ្តល់ការថែទាំឲយយល់អំពីការតស៊ូមតិនៅក្នុងការ អប់រំ គឺ និងអ្វីដែលជាការរំពឹងទុករបស់សិស្សានុសិស្សចាប់ពីមត្តេយ្យសិក្សារហូតដល់វិទ្យាល័យ។ ភាសាអង់គ្លេស (PDF)

- **ការណែនាំដល់សេវាគាំទ្រកុមារសម្រាប់អ្នកផ្តល់ការថែទាំដែលជាសាច់ញាតិ** (DSHS 22-1143) គឺសេវាអ្វីខ្លះដែលផ្នែកគាំទ្រកុមារ (DCS) របស់ DSHS អាចផ្តល់ជូនអ្នកបាន ប្រសិនបើអ្នកកំពុងថែទាំកូនរបស់សាច់ញាតិ។ ភាសាអង់គ្លេស (PDF)

- **សាច់ញាតិជាឪពុកម្តាយ ៖ ការណែនាំអំពីធនធានសម្រាប់សាច់ញាតិដែលកំពុងចិញ្ចឹមកុមារនៅក្នុងរដ្ឋវ៉ាស៊ីនតោន** (DSHS 22-996)។ ស្យេវតេវាស្តើងដែលមាន 75 ទំព័រ គឺជាការណែនាំអំពីធនធានជាច្រើនសម្រាប់អ្នកផ្តល់ការថែទាំដែលជាសាច់ញាតិ។

- **ជម្រើសសម្រាប់ដីម្ងនជីតា និងអ្នកផ្តល់ការថែទាំដែលមិនមែនជាឪពុកម្តាយផ្ទាល់ខ្លួន ៖ ការណែនាំផ្នែកច្បាប់សម្រាប់រដ្ឋវ៉ាស៊ីនតោន** គឺជាការបោះពុម្ពផ្សាយដែលមិនមែនជារបស់ DSHS សម្រាប់សាច់ញាតិដែលចិញ្ចឹមកុមារដែលពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់។ ការណែនាំនេះអាចរកបានដោយឥតគិតថ្លៃតាមប្រព័ន្ធអ៊ីនធឺណិត នៅ (ចុច "ឧបករណ៍ និងធនធាន" បន្ទាប់មក "ច្បាប់ត្រួសារ")។ សំណោចម្ចងនៃការបោះពុម្ពសម្រាប់អ្នកដែលមិនមែនជាសាច់ញាតិក៏អាចរកបានពី សម្លេងច្បាប់ក្នុងតម្លៃ $10 (រួមបញ្ចូលទាំងថ្លៃដឹកជញ្ជូន) ផងដែរ សូមទាក់ទងសម្លេងច្បាប់តាមរយៈ Voice at info@legalvoice.org ឬ 206-682-9552, ខ្សែបន្ត 102។

ពត្ម៌ព័ត៌មានឥតគិតថ្លៃរួមបញ្ចូលទាំងការណែនាំផ្នែកច្បាប់របស់សម្លេងច្បាប់ សម្រាប់រដ្ឋវ៉ាស៊ីនតោន DVD ជម្រើសផ្នែកច្បាប់ រួមជាមួយកូនស្យេវតេវ ផ្សព្វផ្សាយដែលពាក់ព័ន្ធនានាអាចត្រូវបានស្នើសុំតាមរយៈព័ត៌មានទំនាក់ទំនង របស់រដ្ឋបាលមនុស្សចាស់ និងការគាំទ្ររយៈពេលវែងខាងក្រោម។

សំណួរ?

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖

- **Shelley Arneson** ៖ រដ្ឋបាលរបស់កុមារ/DSHS 360-902-8109 ឬ shelley.arneson@dshs.wa.gov
- **Tom Berry** ៖ រដ្ឋបាលសេវាសេដ្ឋកិច្ច/ DSHS តាមរយៈលេខ 360-725-4617 ឬ tom.berry@dshs.wa.gov
- **Jage Curl** ៖ រដ្ឋបាលសេវាសេដ្ឋកិច្ច/DSHS តាមរយៈលេខ 360-725-4589 ឬ jage.curl@dshs.wa.gov
- **Kevin Cornell** ៖ អាជ្ញាធរថែទាំសុខភាព តាមរយៈលេខ 360-725-1423 ឬ kevin.cornell@hca.wa.gov
- **Hilarie Hauptman** ៖ រដ្ឋបាលមនុស្សចាស់ និងការគាំទ្ររយៈពេលវែង/ DSHS តាមរយៈលេខ 800-422-3263 ឬ 360-725-2556 ឬ hilarie.hauptman@dshs.wa.gov

Washington State Department of Social & Health Services
Transforming lives

DSHS 22-1120 CA (Rev. 10/16) Cambodian